**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ១៦ "ដក្រ៦"

ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២០

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣១២

ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៩

សំណុំរឿងស៊ើបសួរលេខ ២១៦៩

ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៩

សំណុំរឿងជំនុំជម្រះលេខ ២៨៧២

ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៩

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង០០ នាទីរសៀល នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣១២ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] សុភ័ក្ត្រ ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរក្រុមសំដែង ទីកន្លែងកំណើត នៅសង្កាត់ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] សារ៉េត "ស" ម្តាយឈ្មោះ [redacted] រានី "រ" ជាទីតិជន ទោសពីមុនគ្មាន។ (ដីកាបង្គាប់ឲ្យឃុំខ្លួន លេខ ៥១១២ (ជ) ដ.ឃ.ង/ ០៣.០៦.២០១៩ )

ជាប់ចោទពីបទ៖ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវលេខ១៥៤ កែងផ្លូវលេខ១៣ ភូមិទី០៥ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃ០១ ខែមិថុនា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- ជនរងគ្រោះ៖ ឈ្មោះ [redacted] PATRICK HRYCIW ភេទប្រុស ជនជាតិអាមេរិក មានទីលំនៅផ្លូវលេខ ១៣ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ៖ លោកមេធាវី [redacted]។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង០១ និង៤៥នាទី ឈ្មោះ [redacted] សុភ័ក្ត្រ ភេទប្រុស អាយុ ២៥ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាក ICON ពណ៌សលាយ លឿង ពាក់ស្លាកលេខ ភ្នំពេញ ១CV-៥១១៧។ លុះជិះដល់ចំណុចផ្លូវលេខ១៥៤ កែងផ្លូវលេខ១៣ ភូមិទី០៥ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឈ្មោះ [redacted] សុភ័ក្រ បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃម៉ាក PocoPhone ពណ៌ក្រហម ពីជនបរទេសម្នាក់ដែលកំពុងដើរកាន់ទូរស័ព្ទដៃតាមផ្លូវ។ បន្ទាប់ពីធ្វើសកម្មភាពរួច ឈ្មោះ [redacted] សុភ័ក្ត្រ ជិះម៉ូតូគេចខ្លួនបានបន្តិច ក៏ត្រូវបានជនរងគ្រោះស្រែកថាចោរៗ ភ្លាមៗ នោះសមត្ថកិច្ចកំពុងល្បាតនៅក្បែរនោះ បានធ្វើការអន្តរាគមន៍ចាប់ខ្លួនជនជាប់ចោទ ព្រមទាំងវត្ថុតាងតែម្តង។

-បានឃើញ របាយការណ៍សំយោគលេខ ០៦២/១៩ រ.ប.ក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២២១០ អ.យ.ក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៥៣៦ អ.យ.ង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៣៧៣ "ផ" ដ.ស ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយថា៖ ខ្លួនមិនបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់គេឡើយ។ ខ្លួនមិនបានចាំថ្ងៃកើតហេតុឡើយ គ្រាន់តែដឹងថាក្នុងខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ០១ និង៣០នាទីយប់ ដោយពេលនោះខ្លួនផឹកគ្រឿងស្រវឹងបន្តិចដែរ និងបានជិះម៉ូតូចេញពីចំនុចម្តុំបឹងកេងកង មកតាមផ្លូវមាត់ទន្លេ ហើយក៏បានជិះម៉ូតូទៅបុកជនបរទេសបណ្តាលឱ្យដួល មានរបួសជើង និងបណ្តាលឱ្យធ្លាក់ទូរស័ព្ទពីដៃ ទើបគេចោទប្រកាន់ខ្លួនថាបានឆក់ទូរស័ព្ទដៃគេ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ជនជាប់ចោទបានឆ្លើយបដិសេធថាមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ប៉ុន្តែចម្លើយនៅមន្ត្រីនគរបាល និងដំណាក់កាលផ្សេងៗ បានបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។ ក្នុងនាមជាតំណាងអយ្យការ នៅតែរក្សាបទចោទប្រកាន់ដូចមាន ក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ២៥៣៦ អ.យ.ង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការសម្រេចទៅតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា៖ កូនក្តីខ្លួនឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយបដិសេធអំពីទង្វើរបស់ខ្លួនដែលបានចោទប្រកាន់ថាបានឆក់ទូរស័ព្ទរបស់ជនរងគ្រោះ។ ប៉ុន្តែកូនក្តីខ្លួនបានទទួលស្គាល់ថាខ្លួនពិតជាបានជិះម៉ូតូបុកជនបរទេសរហូតធ្លាក់ទូរស័ព្ទដៃប្រាកដមែន។ នេះអាចបញ្ជាក់ថា ការចោទប្រកាន់លើកូនក្តីខ្លួនថាបានប្រព្រឹត្តអំពើឆក់ទូរស័ព្ទដៃជនរងគ្រោះ គឺមិនត្រឹមត្រូវឡើយ ហើយក៏ពុំមានភស្តុតាងបញ្ជាក់ថាកូនក្តី ខ្លួនបានប្រព្រឹត្តអំពើនេះដែរ។ តាមអង្គហេតុនៃរឿង និងចម្លើយរបស់កូនក្តីខ្លួនឈ្មោះ [redacted] សុភ័ក្រ្ត អាចបញ្ជាក់បានថា ពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ក្នុងការចោទប្រកាន់កូនក្តីខ្លួនឡើយ ដូចនេះក្នុងមានជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យតុលាការសម្រេចអោយកូនក្តីខ្លួនឈ្មោះ [redacted] សុភ័ក្រ រួចផុតពីបទចោទប្រកាន់។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត បាននិយាយសំដីចុងក្រោយបង្អស់ថា: សុំឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

០១/ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៣៧៣ “ផ” ជ.ជ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ និងដីកាសន្និដ្ឋានស្ថាពរលេខ២៥៣៦ អ.យ.ង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់ជនជាប់ចោទ ឈ្មោះ [redacted] សុភ័ក្រ្ត ពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវលេខ១៥៤ កែងផ្លូវលេខ១៣ ភូមិទី០៥ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃ០១ ខែមិថុនា ឆ្នាំ២០១៩។

០២/ ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយថា៖ ខ្លួនមិនបានធ្វើសកម្មភាព ឆក់ទូរស័ព្ទដៃរបស់គេឡើយ។ ខ្លួនមិនបានចាំថ្ងៃកើតហេតុឡើយ គ្រាន់តែដឹងថាក្នុងខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ០១ និង៣០នាទីយប់ ដោយពេលនោះខ្លួនផឹកគ្រឿងស្រវឹងបន្តិចដែរ និងបានជិះម៉ូតូចេញពីចំនុចផ្ទុំបឹងកេងកង មកតាមផ្លូវមាត់ទន្លេ ហើយក៏បានជិះម៉ូតូទៅបុកជនបរទេសបណ្តាលឱ្យដួល មានរបួសជើង និងបណ្តាលឱ្យធ្លាក់ទូរស័ព្ទពីដៃ ទើបគេចោទប្រកាន់ខ្លួនថាបានឆក់ទូរស័ព្ទដៃគេ។

០៣/ របាយការណ៍សំយោគលេខ ០៦២/១៩របក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ បានសន្និដ្ឋានថា ឈ្មោះ [redacted] សុភ័ក្រ្ត ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស ប្រាកដមែន។

០៤/ ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយបដិសេធនាពេលសវនាការថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ព្រមទាំងបានបដិសេធចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ទៀតផង ដែលចម្លើយនេះគ្រាន់តែជាការដោះសារតែប៉ុណ្ណោះ ពុំមានភស្តុតាងណាមួយបញ្ជាក់ឡើយ។

០៥/ តាមអង្គហេតុនៃរឿង ចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងផ្សេងៗ បានបង្ហាញអោយឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត ពិតជាបានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃរបស់ ជនរងគ្រោះផងដែរ។ អំពើរបស់ជនជាប់ចោទឈ្មោះ ណុន សុភ័ក្រ្ត ដែលបានប្រើហិង្សា ដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់ជនរងគ្រោះ គឺជាបទល្មើសៈ លួចមានស្ថានទម្ងន់ទោស ដែលមានចែងឱ្យផ្តន្ទាទោសក្នុងមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

០៦/ ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត ជានីតិជន និងមានស្មារតីយល់ ដឹងគ្រប់គ្រាន់ទៅលើ អំពើប្រព្រឹត្តរបស់ខ្លួនកាលពីថ្ងៃ០១ ខែមិថុនា ឆ្នាំ២០១៩ ដែលអំពើនេះបានធ្វើឱ្យប៉ះពាល់ដល់ សន្តិសុខ សង្គម សណ្តាប់ធ្នាប់សាធារណៈ និងប្រឆាំងទៅនឹងច្បាប់ព្រហ្មទណ្ឌ ទៀតផង ។

០៧/ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត ពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវលេខ១៥៤ កែងផ្លូវលេខ១៣ ភូមិទី០៥ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃ០១ ខែមិថុនា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

០៨/ តំណាងអយ្យការ ស្នើរសុំរក្សាបទចោទប្រកាន់ទុកជាបានការ តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៥៣៦ អ.យ.ង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ គម្បីតុលាការ ពិចារណា និងសម្រេច តាមច្បាប់។

០៩/ ជនរងគ្រោះមិនបានចូលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងរដ្ឋប្បវេណី ដូចនេះតុលាការពុំចាំបាច់ពិចារណា និងសម្រេចអំពីសំណងរដ្ឋប្បវេណីឡើយ។

១០/ វត្ថុចាប់យករួមមាន៖ ម៉ូតូ ០១គ្រឿង ម៉ាក HONDA ICON ពណ៌សលាយ លឿង ពាក់ស្លាកលេខ ភ្នំពេញ ១CV-៥១១៧ លេខតួ ៨០១១៧១៦៦ និងលេខម៉ាស៊ីន ៨០១១៧១។ តុលាការយល់ឃើញថា មិនមែនជាវត្ថុតាងនៃការប្រព្រឹត្តបទល្មើស គប្បីតុលាការ សម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ តាមបញ្ញតិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១/ ផ្តន្ទាទោស៖ ឈ្មោះ [redacted] សុភ័ក្ត្រ ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៣ឆ្នាំ (បីឆ្នាំ) ពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវលេខ១៥៤ កែងផ្លូវលេខ១៣ ភូមិទី០៥ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃ០១ ខែមិថុនា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២/ វត្ថុចាប់យកមាន៖ ម៉ូតូ ០១គ្រឿង ម៉ាក HONDA ICON ពណ៌សលាយ លឿង ពាក់ស្លាកលេខ ភ្នំពេញ ១CV-៥១១៧ មានលេខតួ ៨០១១៧១៦៦ និងលេខម៉ាស៊ីន ៨០១១៧១ ។

សម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ តាមបញ្ញតិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ, មេធាវីការពារសិទ្ធិជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រាៈ | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែ មករា ឆ្នាំ ២០២០

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]